មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

០៥-៥-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/០៥០៤/០៧០ ស្ដីពីការកំណត់រមណីយដ្ឋានប្រាសាទកោះកែរ	៨០០
១៤-៥-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/០៥០៤/០៧៨ ស្ដីពីការតម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ឯក ជាកិច្ច បច្ឆាមរណៈជូនសពឯកឧត្ដម ឧត្ដមសេនីយ៍ទោ **ឡាយ ម៉ុនសុខ**	៨០៥
១៤-៥-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/០៥០៤/០៧៩ ស្ដីពីការតម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈជូនសព ឧត្ដមសេនីយ៍ត្រី **ជេត តិន**	៨០៦
១៤-៥-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/០៥០៤/០៨០ ស្ដីពីការតម្លើងឋានន្តរសក្តិ ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ	៨០៧
១៤-៥-២០០៤	-ព្រះរាជក្រឹត្យ នស/រកត/០៥០៤/០៨១ ស្ដីពីការតែងតាំង លោក **ទេង ស្រ៊ុន** ជា ឧកញ៉ា	៨០៨

II. រាជរដ្ឋាភិបាល

១៧-៥-២០០៤	-អនុក្រឹត្យលេខ ២៤៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៨០៩
១៧-៥-២០០៤	-អនុក្រឹត្យលេខ ២៥០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៨១០
១៧-៥-២០០៤	-អនុក្រឹត្យលេខ ២៥១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៨១១
១៧-៥-២០០៤	-អនុក្រឹត្យលេខ ២៥២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៨១២
១៨-៥-២០០៤	-អនុក្រឹត្យលេខ ២៥៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៨១៣
១៨-៥-២០០៤	-អនុក្រឹត្យលេខ ២៥៤ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៨១៤
១៨-៥-២០០៤	-អនុក្រឹត្យលេខ ២៥៥ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ	៨១៥
១៨-៥-២០០៤	-អនុក្រឹត្យលេខ ២៥៦ អនក្រ.តត ស្ដីពីការជូនមេដាយការងារ	៨១៦
១៨-៥-២០០៤	-អនុក្រឹត្យលេខ ២៥៧ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៨១៨
១៩-៥-២០០៤	-អនុក្រឹត្យលេខ ២៥៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៨២០
១៩-៥-២០០៤	-អនុក្រឹត្យលេខ ២៥៩ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី	៨២១
១៩-៥-២០០៤	-អនុក្រឹត្យលេខ ២៦០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៨២៣
១៩-៥-២០០៤	-អនុក្រឹត្យលេខ ២៦១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៨២៤
១៩-៥-២០០៤	-អនុក្រឹត្យលេខ ២៦២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៨២៦
២០-៥-២០០៤	-អនុក្រឹត្យលេខ ២៦៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៨២៧
២០-៥-២០០៤	-អនុក្រឹត្យលេខ ២៦៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៨២៩
២០-៥-២០០៤	-អនុក្រឹត្យលេខ ២៦៥ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៨៣០

២១-៥-២០០៤ -អនុក្រឹត្យលេខ ២៦៦ អនក្រ.តត ស្ដីពីការតែងតាំងសមាជិកបន្ថែម គណៈកម្មការកម្ពុជា សំរាប់ស្រាវជ្រាវរួមគ្នាជាមួយភាគីថៃ អំពីវិស័យវប្បធម៌ ៨៣១
២១-៥-២០០៤ -អនុក្រឹត្យលេខ ២៦៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៨៣៣
២១-៥-២០០៤ -អនុក្រឹត្យលេខ ២៦៨ អនក្រ.តត ស្ដីពីការលុបឈ្មោះមន្ត្រីរាជការ ដែលទទួលមរណភាព ៨៣៤

ព្រះរាជក្រឹត្យ

នស/រកត/០៥០៤/០៧០

ស្តីពី

ការកំណត់រមណីយដ្ឋានប្រាសាទកោះកេរ

*****

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការបង្កើតនិងកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១១ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាព ពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០០៤

ត្រាស់បង្គាប់

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

កំណត់រមណីយដ្ឋានវប្បធម៌នៃប្រាសាទកោះកែរ ជារមណីយដ្ឋានការពារ ស្ថិតក្នុងឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ ។

មាត្រា ២.-

ការបង្កើតរមណីយដ្ឋាននេះមានគោលបំណង :

- អភិរក្សកេរដំណែលវប្បធម៌ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និងលើកតម្លៃតំលៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្ស ទេសភាពវប្បធម៌ និង អភិវឌ្ឍន៍តំបន់ទេសចរណ៍
- ការពារបរិស្ថានធម្មជាតិក្នុងតំបន់ តាមស្ថានភាពភូមិសាស្ត្រជាក់ស្ដែង ។

ជំពូកទី ២

ការកំណត់តំបន់

មាត្រា ៣.-

ត្រូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍន៍រមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រងតំបន់ តាមចំណាត់ថ្នាក់តំបន់ដែលត្រូវការពារ ។

មាត្រា ៤.-

រមណីយដ្ឋានការពារប្រាសាទកោះកេរត្រូវចាត់ជា ៣ (បី) តំបន់ផ្សេងៗគ្នា ហើយត្រូវទទួលកំរិតការពារខុសៗគ្នា :

១- តំបន់ស្នូល : ជាតំបន់ដែលមានប្រាសាទធំ ហៅថាតំបន់ " ក " និងរហាល ហៅថាតំបន់ " ខ " ។

តំបន់ទាំង២ (ពីរ) ត្រូវបានកំណត់ដូចខាងក្រោមនេះ :

តំបន់ ក : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

A1 (450190 ; 1523180) , A2(450100 ; 1523620)
A3 (450730 ; 1523730) , A4(450790 ; 1523280)

តំបន់ ខ : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

B1 (450710 ; 1523226) , B2 (451245 ; 1523343)
B3 (451608 ; 1522253) , B4 (451071 ; 1522106)

តំបន់ស្នូលនេះ មានផ្ទៃក្រលាសរុប ៩២ ហិកតា ៦២ អារ (កៅសិបពីរ ហិកតា ហុកសិបពីរ អារ) ។

តំបន់ " ក " និង " ខ " ជារមណីយដ្ឋានការពារ ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។

២- តំបន់ទ្រនាប : ជាតំបន់ឧទ្យានបុរាណវិទ្យា សំបូរដោយប្រាសាទតូចៗ និងសំណល់បុរាណវត្ថុជាច្រើនដែលបានបន្សល់ទុកនូវដាន ស្នាកស្នាម ឬកប់ក្នុងដី រាក់ឬជ្រៅនៅតាមទីវាល ព្រៃឈើជាដើម ហើយដែលអ្នកបុរាណវិទ្យា បានរកឃើញ និងពុំទាន់រុករកឃើញនៅឡើយ ។

តំបន់នេះមានផ្ទៃក្រឡា ៣.៥០៧ ហិកតា ៦៣អារ (បីពាន់ប្រាំរយប្រាំពីរហិកតា និងហុកសិបបីអារ) ។

តំបន់នេះស្ថិតនៅក្រៅបរិវេណតំបន់ " ក " និងតំបន់ " ខ " នៃតំបន់ស្នូលហើយស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច :

C (448000 ; 1526000) , D (448000 ; 1520000)
E (454000 ; 1520000) , F (454000 ; 1526000)

តំបន់នេះសម្បូរដោយសំណល់បុរាណវត្ថុ ដែលត្រូវការពារ ទប់ស្កាត់និងការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍន៍មិនសមស្រប ។

៣- តំបន់លោប : ជាតំបន់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ដោយរក្សាជីវភាព មុខរបរអាជីវកម្មតាមទំនៀមទំលាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ ។

តំបន់នេះស្ថិតនៅក្រៅពីបរិវេណដែលមាននិយាមការចំណុច C D E F ចម្ងាយ ១.៥០០ម៉ែត្រ (មួយពាន់ប្រាំរយ ម៉ែត្រ) ។

តំបន់នេះជាគោលដៅថែរក្សាបេតិកភ័ណ្ឌវប្បធម៌ និងធម្មជាតិ តាមរយៈការចាត់ចែងវិធានការ ដើម្បីជំរុញការអភិវឌ្ឍន៍ឱ្យមាននិរន្តរភាព និងមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

ផែនទីកំណត់តំបន់រមណីយដ្ឋានប្រាសាទកោះកេរ មានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

ជំពូកទី ៣
ការគ្រប់គ្រង ថែទាំ និង ការពារ

មាត្រា ៥.-

ការអភិរក្សរាល់តំបន់នីមួយៗសុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និងការពារ ស្របតាមទិសដៅចំណាត់ថ្នាក់តំបន់ ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ និងគិតនៃសារៈសំខាន់ដោយឡែកៗទាំងខាង បុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ទ្រព្យសម្បត្តិធម្មជាតិ គោរពនូវសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និងលើកស្ទួយរមណីយដ្ឋានការពារឱ្យមានតំលៃកាន់តែខ្ពស់ឡើង ។

មាត្រា ៦.-

ត្រូវអនុវត្តនូវនយោបាយរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំនិងការពារ ដោយកំណត់ភាពម្ចាស់ការទទួលខុសត្រូវរបស់បណ្តាស្ថាប័នមានសមត្ថកិច្ច ដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈទទួលអនុវត្តផ្ទាល់ ដោយផ្អែកលើមាត្រា ៥ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ។

បែបបទនិងនីតិវិធីនៃការគ្រប់គ្រង ថែទាំ និងការការពាររមណីយដ្ឋានប្រាសាទកោះកែរ ក្នុងបណ្តាមាត្រាខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៤
ការកែប្រែតំបន់

មាត្រា ៧.-

បរិវេណ និងរាល់សកម្មភាពរបស់តំបន់និមួយៗនៃរមណីយដ្ឋានការពារប្រាសាទកោះកែរ អាចពិនិត្យឡើងវិញ ហើយកែប្រែបាន ដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាពជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាព ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ ។

ការកែប្រែតំបន់ និងរាល់សកម្មភាពពាក់ព័ន្ធនិងរមណីយដ្ឋានប្រាសាទកោះកែរ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

មាត្រា ៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៩.-

សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃ ឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ [illegible]

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ: ៥៧ . ចល

...ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] សាន់

ព្រះរាជក្រឹត្យ

នស/រកត/០៥០៤/០៧៤

យើង

ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**
រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរស័ក្តិ **ថ្នាក់ឧត្តមសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈជូនសព :
-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ឡាយ ម៉ិនសុខ** អត្តលេខ ០០០០៧៣

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រស.០៤.០៥.០៧៤

លេខៈ ៥៨ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៥០៤/០៣៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជាកិត្តិយសបរមរណៈជូនសព ÷
- ឧត្តមសេនីយ៍ត្រី ខេត តិន អត្តលេខ ០០០០៨៣៨

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែឧសភាឆ្នាំ ២០០៤

គួរព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រកស.០៤.០៥.០៣៩

លេខៈ ៥៩ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាវី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៥០៤/០៩០

យើង

ព្រះបាទសម្តេច នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

ក_ ថ្នាក់ឧត្តមសេនីយ៍ឯក :

១-ឧត្តមសេនីយ៍ទោ ខៀវ សុភ័គ អត្តលេខ ០០៧២
២-ឧត្តមសេនីយ៍ទោ សុខ ផល អត្តលេខ ០០៥១
៣-ឧត្តមសេនីយ៍ទោ ស៊ុម សុជល អត្តលេខ ០០៤៣

ខ_ ថ្នាក់ឧត្តមសេនីយ៍ទោ :

១-ឧត្តមសេនីយ៍ត្រី គីម សំណាង អត្តលេខ ០០៦១
២-ឧត្តមសេនីយ៍ត្រី យុន ណន្ទី អត្តលេខ ០០៧២
៣-ឧត្តមសេនីយ៍ត្រី អ៊ុក គឹមលេខ អត្តលេខ ០០៣៤

គ_ ថ្នាក់ឧត្តមសេនីយ៍ត្រី :

១-វរសេនីយ៍ឯក ឈិម សារ៉ាក់ អត្តលេខ ០១៤៤

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

លេខ: ៥៥ ចព ហត្ថលេខា និងព្រះរាជលញ្ឆករ

ដើម្បីចម្លងចែក

៣ក្រ.០៤.០៥.០៩០ ជា ស៊ីម

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវឌី តាង

ព្រះរាជក្រឹត្យ

នស/រកត/០៥០៤/០៩១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោក ខេង ស្រ៊ិន

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៤
ឡចព្រះបរមនាម និង តាមព្រះរាជក្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខៈ ៦៤ ចល
ចរស.០៤ ០៥.០៩១
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឥណ្ឌី ហាន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤៩ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី OSANAI MIEKO ប្រធានអង្គការ JHP ជប៉ុន ដែលបានផ្តល់ថវិកាចំនួន ៣៤.០៦៦ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ ខ្នង និង បង្គន់អនាម័យ ០១ ខ្នង ជូនសាលាបឋមសិក្សាជា-ចក ក្នុងឃុំរការខ្នុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ដូចក្នុងមាត្រា១ និង មាត្រា២

រាជកិច្ច

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥០ . អនក្រ . តត

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី OSANAI MIEKO ប្រធានអង្គការ JHP ជប៉ុន ដែលបានផ្តល់ថវិកាចំនួន ៣១.០៨០ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ ខ្នង មាន ០៥ បន្ទប់ បង្គន់អនាម័យ ០១ ខ្នង មាន ០៤ បន្ទប់ និង អណ្តូងទឹកស្អាតមួយ ព្រមទាំងបំពាក់សម្ភារៈសិក្សាគ្រប់គ្រាន់ផង ជូនសាលាបឋមសិក្សាទ័ពមាន ក្នុងឃុំទ័ពមាន ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ , ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ដូចក្នុងមាត្រា១ និង មាត្រា២

រាជកិច្ច

ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៥១. អនក្រ.តត

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនលោក **សុខ ម៉ន** សប្បុរសជន នៅខេត្តបាត់ដំបង ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារ ០១ខ្នង ធ្វើអំពីបេតុង មាន ០៤បន្ទប់ នៅក្នុងបរិវេណ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តបាត់ដំបង ចំណាយអស់ ទឹកប្រាក់ ចំនួន ២០.០០០ ដុល្លារ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវ អនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចក្នុងមាត្រា១ និងមាត្រា២
រាជកិច្ច
ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥២.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប័ណ្ណាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគធនធាន ផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យព្រះពុទ្ធសាសនា នៅខេត្តកំពត ចំណាយអស់ ទឹកប្រាក់សរុបចំនួន ៨៥.៦២៥ ដុល្លារ ដូចមានរាយនាមខាងក្រោម ៖

១ មហាឧបាសក **យិន នេន**

២ មហាឧបាសិកា **ប្រាក់ ចំឡង**

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន រដ្ឋសភា
ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
ដូចមាត្រា ១ និង មាត្រា ២
[illegible]
[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៤៣ អនក្រ.តត

អនុក្រឹត្យ
ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រភេទ និងជូនសប្បុរសជនចំនួន ០៧ រូប ដែលបានបរិច្ចាគធនធាន ចូលរួមជួយកសាងអគាររៀន១ និង ព្រះពុទ្ធរូបអង្គធំ សាងពីមាស ប្រាក់ លង្ហិន មានបណ្ដោយ ១៩ ម៉ែត្រ និង កំពស់ ៣,៥០ ម៉ែត្រ នៅក្នុងពុទ្ធមណ្ឌលកម្ពុជា ឃុំដីឥដ្ឋ ស្រុកគៀនស្វាយ ខេត្តកណ្ដាល ដូចមានរាយព្រះនាម និង នាមខាងក្រោម ÷

ក. មេដាយមាសស្ថាបនាជាតិ :

១	ព្រះភិក្ខុសុវណ្ណជោតិ	**នួន**	**នួច**	បច្ច័យចំនួន	៤០.៧០០ ដុល្លារ
២	មហាឧបាសក	**យិត**	**ឆេង**	ទឹកប្រាក់ចំនួន	១៥១.១២៥ ដុល្លារ

ខ. មេដាយសំរិទ្ធស្ថាបនាជាតិ :

១	លោក	**ឆេង**	**ហាក់**	ទឹកប្រាក់ចំនួន	១ ៦៥០ ដុល្លារ
២	លោក	**ខៀវ**	**សារី**	ទឹកប្រាក់ចំនួន	១.៦០០ ដុល្លារ
៣	លោក	**ញៀង**	**បូទីន**	ទឹកប្រាក់ចំនួន	១.៦០០ ដុល្លារ
៤	លោក	**គីមសុន**	**ណារីគុណ**	ទឹកប្រាក់ចំនួន	១.៥៥០ ដុល្លារ
៥	លោក	**សេក**	**សារ៉ុម**	ទឹកប្រាក់ចំនួន	១.៥០០ ដុល្លារ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- [illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៥៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

សំរេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សរឫទ្ធិ** ជូនមន្ត្រីដឹកនាំ *"សាលាភ្លើងសិល្បៈ"* ខេត្តបាត់ដំបង ចំនួន ០៤រូប ដែលមានគុណបំណាច់ខ្ពស់ និង ស្នាដៃល្អ ក្នុងការជួយថែរក្សា និង បណ្តុះបណ្តាលមុខជំនាញ សិល្បៈ វប្បធម៌ អក្សរសាស្ត្រខ្មែរ និង ចំណេះដឹងទូទៅ ដល់កុមារកម្ពុជា ដូចមានរាយនាមខាងក្រោម ៈ-

១	លោក	**ឃួន ដេត**	ស្ថាបនិកដំបូងបង្អស់
២	លោក	**ស្រី បណ្ឌិល**	ស្ថាបនិក ទទួលបន្ទុកសិល្បៈ
៣	លោក	**គីម ចាសនា**	ប្រធានការិយាល័យរដ្ឋបាល
៤	លោក	***Jean Christophe SIDOIT***	ទីប្រឹក្សាជនជាតិបារាំង

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួង អប់រំ យុវជន និង កីឡា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចប្រការ១ និងមាត្រា២
រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៥៥៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោកវរសេនីយ៍ទោ **គង់ ជាន** អត្តលេខ ០៤៣៩

២-លោកវរសេនីយ៍ទោ **ឯម ស៊ីមយ៉ុន** អត្តលេខ ០៥០៥

៣-លោកវរសេនីយ៍ទោ **ជា សុខុម** អត្តលេខ ០១០៧៥

៤ លោកវរសេនីយ៍ទោ **អ៊ុក ស៊ីផាន** អត្តលេខ ១២៣៣៧

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង - ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៥៦ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយការងារ

✻ ✻ ✻ ✻ ✻ ✻

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តបាត់ដំបង

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូននាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ចំនួន **៣០ រូប** ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោមនេះ :

១ លោកវរសេនីយ៍ឯក **ឈឹម សារ៉ែត** អនុប្រធាននាយកដ្ឋានបុគ្គលិក
២- លោកវរសេនីយ៍ឯក **ឡាក់ គួយឡេង** អនុប្រធាននាយកដ្ឋានបុគ្គលិក
៣ លោកវរសេនីយ៍ឯក **កុសល គិរីយ** អនុប្រធាននាយកដ្ឋានបុគ្គលិក
៤- លោកវរសេនីយ៍ឯក **អ៊ុំ សំអ៊ុន** អនុប្រធាននាយកដ្ឋានបុគ្គលិក
៥ លោកវរសេនីយ៍ទោ **ម៉ុល សុគន្ធ** នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៦ លោកវរសេនីយ៍ទោ **ហង្ស ពុន្ធា** នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៧- លោកវរសេនីយ៍ទោ **ឃាន់ ឧទ្ធី** នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៨ លោកវរសេនីយ៍ទោ **ហ៊ុត ចាន់វណ្ណា** នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៩ លោកវរសេនីយ៍ទោ **អៅ ម៉ុនសុខ** នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
១០- លោកវរសេនីយ៍ទោ **អ៊ុន ស៊ីរះណន** នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក

១១	លោកវរសេនីយ៍ទោ	អ៊ុក	ស៊ីផា	នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
១២	លោកវរសេនីយ៍ទោ	ឈុប	ទី	នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
១៣-	លោកវរសេនីយ៍ទោ	ម៉ៅ	សំអឿន	នាយការិយាល័យ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
១៤	លោកវរសេនីយ៍ទោ	រស់	សុខា	នាយការិយាល័យ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក
១៥	លោកវរសេនីយ៍ត្រី	សុខ	សារិន	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
១៦	លោកវរសេនីយ៍ត្រី	សេង	សុគន្ធ	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
១៧	លោកវរសេនីយ៍ត្រី	សេង	ឌា	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
១៨	លោកវរសេនីយ៍ត្រី	ឈុន	ម៉ាន់ថន	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
១៩	លោកវរសេនីយ៍ត្រី	កៅ	ម៉ុយឃាង	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
២០-	លោកវរសេនីយ៍ត្រី	សែត	វណ្ណាស័ក្ខ	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
២១-	លោកវរសេនីយ៍ត្រី	ញ៉ៀម	សុខន	អនុប្រធានមន្ទីរពេទ្យព្រះមុនីវង្ស នៃនាយកដ្ឋានសុខាភិបាល
២២	លោកវរសេនីយ៍ត្រី	អ៊ឹម	ឌូ	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង
២៣	លោកវរសេនីយ៍ត្រី	សុវណ្ណ	គីមហាក់	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង
២៤	លោកវរសេនីយ៍ត្រី	សេង	សុន	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង
២៥-	លោកអនុសេនីយ៍ឯក	អ៊ុង	សារុំ	នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក
២៦-	លោកអនុសេនីយ៍ឯក	ខាំដែង	ចន្ទចន្ទ្រី	នាយរងប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ នៃនាយកដ្ឋានជនបរទេស
២៧-	លោកអនុសេនីយ៍ទោ	គីម	ហុង	នាយរងផ្នែក នៃនាយកដ្ឋានបុគ្គលិក
២៨-	លោកអនុសេនីយ៍ទោ	គិត	ហ៊ាង	អធិការរង នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង
២៩-	លោកអនុសេនីយ៍ទោ	ទេព	វណ្ណឌី	នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង
៣០	លោកអនុសេនីយ៍ត្រី	ស៊ុត	ចន្ទតារា	មន្ត្រី នៃនាយកដ្ឋានសុខាភិបាល

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល ៖
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
រាជកិច្ច
ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៥៧.អនក្រ.បក

អនុក្រឹត្យ

